# សាលាបឋមសិក្សា ឃើគប្រាយ (Kirkbride)

**1501 S. 7th Street**
**Philadelphia, PA 19147**
**ទូរស័ព្ទ៖ (២១៥) ៤០០-៧៩៨០**

# កូនសៀវភៅអំពីសិស្សថ្នាក់មត្តេយ្យ សម្រាប់មាតាបិតា

***ថ្ងៃចូលរៀនដំបូងសម្រាប់សិស្សថ្នាក់មត្តេយ្យ គឺថ្ងៃអង្គារ ទី១២ ខែកញ្ញា ២០១៧***

**អាហារពេលព្រឹក**

អាហារពេលព្រឹក ផ្តល់ឲ្យនៅសាលាពីម៉ោង ៧:៤៥ ដល់ ៨:១៥ ជារៀងរាល់ថ្ងៃ។

**ជូនកូនរបស់លោកអ្នកមកសាលា**

សូមជូនកូនរបស់លោកអ្នកទៅកាន់ថ្នាក់រៀនរបស់ពួកគេ ហើយទុកពួកគេនៅមាត់ទ្វារ។ បើសិនជាលោកអ្នកចង់ឲ្យកូនញ៉ាំអាហារពេលព្រឹក លោកអ្នកអាចជូនកូនចុះទៅសាលញ៉ាំអាហារថ្ងៃត្រង់ ហើយសមាជិកបុគ្គលិកនឹងជូនពួកគេទៅកាន់ថ្នាក់រៀននៅម៉ោង ៨:២៥។ **លោកអ្នកអាចនាំកូនរបស់លោកអ្នកទៅកាន់ថ្នាក់រៀនព្រឹកបំផុត នៅម៉ោង ៨។**

**សាលាចាប់ផ្តើមបង្រៀននៅម៉ោង ៨:២៥។** បើសិនជាកូនរបស់លោកអ្នកមកដល់សាលានៅម៉ោង ៨:៣០ ពួកគេនឹងមានការខកខានធ្វើកិច្ចការប្រចាំថ្ងៃអ្វីមួយ ហើយអាចមិនបានដឹងពីផ្នែកដ៏សំខាន់ណាមួយនៃមេរៀន។ (សូមធ្វើយ៉ាងណាឲ្យកូនទៅបន្ទប់ទឹក **មុនពេល**មកកាន់សាលា)។

**បើសិនជាកូនលោកអ្នកមកយឺតពេល (៨:៣៥ ព្រឹក)៖** សូមទៅកាន់តុចុះឈ្មោះជាមួយកូនដើម្បីចុះឈ្មោះ។ យកលិខិតសម្រាប់ការមករៀនយឺត។ នាំកូនរបស់លោកអ្នកទៅកាន់ថ្នាក់រៀន។

**សូមកុំទុកកូនចោល ទោះជានៅពេលណាក៏ដោយ។**

**កំណត់សម្គាល់**

នៅក្នុងម៉ោងរៀន មាតាបិតាត្រូវទៅកាន់ការិយាល័យសាលា បង្ហាញអត្តសញ្ញាណប័ណ្ណ និងសុំការអនុញ្ញាត មុនពេលទៅកាន់ថ្នាក់រៀន។ យើងត្រូវតែសហការគ្នាដើម្បីផ្តល់សុវត្ថិភាពដល់សិស្សទាំងអស់។ សាលាមិនអនុញ្ញាតឲ្យមាតាបិតាទៅទទួលកូនពីថ្នាក់រៀនទេ។

**វិធីទូទៅនៃការមកទទួលកូន**

សាលានឹងឲ្យកូនលោកអ្នកចេញនៅម៉ោង ៣:០០ រសៀល តាមទ្វារធំ។ គ្រូរបស់កូនលោកអ្នកនឹងហៅឈ្មោះពួកគេដើម្បីឲ្យចេញ។ សាលាអនុញ្ញាតឲ្យតែអ្នកដែលលោកអ្នកផ្តល់ឈ្មោះនៅក្នុងបញ្ជីមកទទួលក្មេង ទើបអាចមកទទួលយកកូនរបស់លោកអ្នកនៅពេលចេញពីរៀនបាន។ **អ្នកដែលមកទទួលកូនរបស់លោកអ្នក ត្រូវមានអត្តសញ្ញាណប័ណ្ណជាប់ខ្លួនជារៀងរាល់ថ្ងៃ។**

**អវត្តមាន**

គ្រប់អវត្តមានទាំងអស់ត្រូវមានលិខិតបញ្ជាក់ពីមូលហេតុ ទើបអាចចាត់ទុកថាជាអវត្តមានដោយមានមូលហេតុ។ សូមកុំភ្លេចសរសេរ **ថ្ងៃខែ ឈ្មោះ** និង **មូលហេតុ** នៃអវត្តមានរបស់កូនលោកអ្នកនៅលើលិខិតនោះ។ បើសិនជាមិនយកលិខិតមកទេ គេនឹងកត់ទុកថាជាអវត្តមានគ្មានមូលហេតុ។ អវត្តមានដែលគ្មានមូលហេតុ ត្រូវចាត់ទុកថាជាការគេចសាលា។ យើងខ្ញុំអរគុណ បើមានលិខិតពីមាតាបិតា ឬពីវេជ្ជបណ្ឌិត។ ហើយក៏ជួយឲ្យសាលាទុកចិត្តថា លោកអ្នកបានដឹងថាកូននៅទីណា នៅពេលដែលពួកគេមិនបានមករៀន។ លោកអ្នកអាចដាក់លិខិតនៅក្នុង ក្របដាក់កិច្ចការដែលត្រូវឲ្យយកទៅធ្វើនៅផ្ទះ របស់កូនលោកអ្នក។

**ពេលចេញលេង និង ពេលសម្រាក**

សិស្សមានពេលទៅបន្ទប់ទឹក២ដងក្នុងមួយថ្ងៃ ជាមួយនឹងថ្នាក់រៀនរបស់ពួកគេ។ សិស្សមានពេលចេញលេង២០នាទីជារៀងរាល់ថ្ងៃ មុនពេលញ៉ាំអាហារថ្ងៃត្រង់ តាមរបៀបលេងផងរៀនផង (PlayWorks)។ នៅថ្នាក់មត្តេយ្យ យើងមិនផ្តល់ចំណីឲ្យសិស្សទេ។ សាលាផ្តល់អាហារថ្ងៃត្រង់ដល់សិស្សទាំងអស់ ប៉ុន្តែលោកអ្នកអាចដាក់អាហារថ្ងៃត្រង់ឲ្យកូនបាន បើសិនជាលោកអ្នកចង់ដាក់។

**សម្ភារៈក្មេងលេង**

សូមទុក ប្រដាប់លេង ល្បែងគ្រឿងអេឡិចត្រូនិច លុយ នាឡិកា និង គ្រឿងអលង្ការ នៅផ្ទះ។

## <u>ច្បាប់នៃការស្លៀកពាក់របស់សាលា ឃើតប្រាយ</u>

**សិស្ស<u>ត្រូវតែ</u>ស្លៀកពាក់ឯកសណ្ឋានរបស់ខ្លួនជារៀងរាល់ថ្ងៃ ពីខែកញ្ញា ដល់ ខែមិថុនា។**

- **សិស្សទាំងអស់ត្រូវស្លៀកខោ<u>ពណ៌ខ្មៅ</u>។**
- **ក្មេងស្រី - អាចស្លៀក ខោ សំពត់ ឬ សំពត់/ខោ ដែលមានខ្សែពាក់លើស្មា ពណ៌ខ្មៅ។**
- **អាវបើកក <u>ពណ៌ខៀវ</u>**
- **សិស្សអាចពាក់អាវយឺត<u>ពណ៌ខៀវ</u> ជាមួយខោកៅស៊ូពណ៌ខ្មៅ សម្រាប់ហាត់កីឡានៅថ្ងៃដែលបានកំណត់ឲ្យ។**
- **អាវរងាអាចមានពណ៌ ខៀវ ខ្មៅ ឬ ប្រផេះ ដែលគ្មានមួកគ្របក្បាល ឬ រូបភាពអ្វី។**

**ឯកសណ្ឋានរបស់សាលា ឃើតប្រាយ មានលក់នៅហាង Triple Play Sports អាស័យដ្ឋានលេខ 827 South 9th Street (នៅកាច់ជ្រុងផ្លូវលេខ 9th & Christian) មានប៉ាក់សញ្ញាតំណាងឲ្យសាលារបស់យើងនៅលើអាវ។ សូមទាក់ទងទៅទូរស័ព្ទលេខ (២១៥) ៩២៣-៥៤៦៦ ដើម្បីទិញឯកសណ្ឋានរបស់យើង។ អាវមិនចាំបាច់មានសញ្ញាតំណាងឲ្យសាលានោះទេ។**

****សូមផ្ញើសម្លៀកបំពាក់ទុកផ្លាស់ប្តូរ (ខោត្រនាប់ ខោ អាវ ស្រោមជើង) ក្នុងថង់មានរូតបិទ ដែលមានសរសេរឈ្មោះរបស់កូនលោកអ្នក ដើម្បីទុកក្នុងថ្នាក់រៀន សម្រាប់ពេលដែលត្រូវការ។**